ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ...៣១១........បទ.ប្រក...............

# ប្រកាស
# ស្តីពី
# ការកែសម្រួល និងបំពេញបន្ថែមលេខកូដប្រៃសណីយ៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកែសម្រួល និងបំពេញបន្ថែមលេខកូដប្រៃសណីយ៍ សម្រាប់កំណត់សម្គាល់អាសយដ្ឋានមួយ ឬបណ្តុំអាសយដ្ឋានជាក់លាក់ណាមួយ ឬតំបន់ប្រៃសណីយ៍ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.**

ប្រកាសនេះ មានគោលដៅ ៖

- បង្កើនប្រសិទ្ធភាពអាជីវកម្មប្រៃសណីយ៍និងសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង
- ជួយសម្រួលពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធឺណិត
- ធានាដល់ការបែងចែកបញ្ញើប្រៃសណីយ៍ឱ្យកាន់តែទៀងទាត់ និងទាន់ពេលវេលា
- បង្កលក្ខណៈងាយស្រួលសម្រាប់ការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធតម្រៀបនិង/ឬញែកបញ្ញើប្រៃសណីយ៍តាមបច្ចេកវិទ្យាទំនើប។

**ប្រការ ៣.**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ ក្រសួង ស្ថាប័ន អង្គភាព បុគ្គល និងសាធារណជនទាំងឡាយណាដែលមានតម្រូវការប្រើប្រាស់លេខកូដប្រៃសណីយ៍ ។

**ប្រការ ៤.**

ការកែសម្រួល និងបំពេញបន្ថែមលេខកូដប្រៃសណីយ៍ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍៖

- លក្ខណៈវិទ្យាសាស្ត្រ សាមញ្ញ និងអាចប្រើប្រាស់បានយូរអង្វែង
- ស្ថានភាពប្រជាសាស្ត្រ និងបច្ចុប្បន្នភាពរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ព្រមទាំងមិនត្រួតគ្នាក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- សេចក្តីណែនាំរបស់សហភាពប្រៃសណីយ៍សកល(UPU)និងសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិ
- មានលេខកូដត្រៀមបម្រុងសម្រាប់ឆ្លើយតបនឹងតម្រូវការទៅអនាគត ។

**ប្រការ ៥.**

លេខកូដប្រៃសណីយ៍ សរសេរជាលេខឡាតាំងចំនួន៦ខ្ទង់។ ទម្រង់លេខកូដប្រៃសណីយ៍ទាំង៦ខ្ទង់ ត្រូវបានកំណត់ដូចខាងក្រោម៖

- លេខពីរខ្ទង់ដំបូងរាប់ពីឆ្វេងទៅស្តាំ ជាលេខកូដសម្គាល់តំបន់ប្រៃសណីយ៍ រាជធានី ខេត្ត
- លេខចំនួនបួនខ្ទង់រាប់ពីឆ្វេងទៅស្តាំ ជាលេខកូដសម្គាល់តំបន់ប្រៃសណីយ៍ក្រុង ស្រុក ខណ្ឌ
- លេខទាំងប្រាំមួយខ្ទង់សម្គាល់ឱ្យទីតាំងអាសយដ្ឋានមួយ ឬបណ្តុំអាសយដ្ឋានជាក់លាក់ណាមួយ ឬជាលេខកូដប្រៃសណីយ៍កំណត់សម្គាល់តំបន់ប្រៃសណីយ៍ ឃុំ សង្កាត់មួយ។

សៀវភៅលេខកូដប្រៃសណីយ៍នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៧ ភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៦.**

លេខកូដប្រៃសណីយ៍ ចាំបាច់ត្រូវធ្វើការកែសម្រួល និងបំពេញបន្ថែម ក្នុងស្ថានភាពដូចខាងក្រោម៖

- ករណីមានការបំបែក/បង្រួមអង្គភាពរដ្ឋបាល ឬបង្កើតអង្គភាពរដ្ឋបាលថ្មី ដែលអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គភាពថ្មីនោះ ត្រូវកំណត់លេខកូដប្រៃសណីយ៍ដោយប្រើប្រាស់លេខកូដត្រៀមបម្រុង និងត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ

- ករណីមានការផ្លាស់ប្តូរភូមិសាស្ត្ររដ្ឋបាល ឬកែសម្រួលព្រំប្រទល់រដ្ឋបាល អង្គភាពរដ្ឋបាលដែលត្រូវដាក់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធថ្មី ត្រូវកំណត់ឬកែតម្រូវលេខកូដប្រៃសណីយ៍ឱ្យស្របតាមរចនាសម្ព័ន្ធថ្មីនោះ
- លេខកូដប្រៃសណីយ៍ណាដែលលែងប្រើប្រាស់ ត្រូវរក្សាទុកជាធនធានបម្រុង។

**ប្រការ ៧.-**

ការកែសម្រួល និងបំពេញបន្ថែមលេខកូដប្រៃសណីយ៍ដូចមានចែងនៅក្នុងប្រកាសនេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ ។

អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ និងប្រៃសណីយ៍កម្ពុជា ត្រូវសហការជាមួយស្ថាប័នឬអង្គភាពពាក់ព័ន្ធ ដើម្បីណែនាំផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅទូទាំងប្រទេស ព្រមទាំងចាត់ចែងជូនដំណឹងទៅដៃគូអន្តរជាតិនានាអំពីកាលបរិច្ឆេទដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវការកែសម្រួលនិងបំពេញបន្ថែមលេខកូដប្រៃសណីយ៍នៅកម្ពុជា។

**ប្រការ ៨.-**

សៀវភៅលេខសម្គាល់តំបន់ប្រៃសណីយ៍បោះពុម្ព ឆ្នាំ១៩៩៧ ត្រូវឈប់ប្រើត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ ។

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ប្រធានវិទ្យាស្ថានជាតិ ប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត អគ្គនាយកប្រៃសណីយ៍កម្ពុជា និងគ្រប់ប្រតិបត្តិករប្រៃសណីយ៍ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
  «ដើម្បីជូនជ្រាប»
- ដូចប្រការ ៩«ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ